**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ទទួលបន្ទុកកិច្ចការបរទេសនៃសភាបង់ក្លាដែស ចូលជួបសម្តែងការគួរសម

នៅព្រឹកថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ **ឯកឧត្តម** Muhammad Faruk Khan ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការបរទេសនៃសភាបង់ក្លាដែស ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ ក្នុងឱកាសដែលឯកឧត្តមអញ្ជើញមកបំពេញទស្សនកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ដំណើរទស្សនកិច្ចផ្លូវការរបស់ឯកឧត្តម Muhammad Faruk Khan មកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលរួមចំណែកជួយពង្រឹងពង្រីកនូវទំនាក់ទំនងទ្វេភាគីកម្ពុជា-បង់ក្លាដែស ឲ្យកាន់តែរីកចម្រើនថែមទៀត។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដល់គណៈប្រតិភូ ដែលបានឆ្លៀតឱកាសទស្សនកិច្ចអញ្ជើញចូលរួមក្នុងពិធីរំលឹកខួបលើកទី៤១ នៃទិវាជ័យជំនះ ៧ មករា។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ចូលរួមអបអរសាទរ និងបានជូនពរសព្វសាធុការដល់រដ្ឋាភិបាល និងប្រជាជនបង់ក្លាដែសក្នុងឱកាសបង់ក្លាដែស រៀបចំពិធីប្រារព្ធខួប១០០ ឆ្នាំនៃថ្ងៃកំណើតរបស់**ឯកឧត្តម Bangabandhu Sheikh Mujibur Rahman** បិតាជាតិបង់ក្លាដែសក្នុងឆ្នាំ២០២០ នេះ។

**ឯកឧត្តម ប្រធានគណៈប្រតិភូ** បានសម្តែងនូវសេចក្តីសោមនស្សរីករាយ និងមានកិត្តិយសដែលបានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា គាប់ជួនកម្ពុជាប្រារព្ធខួបទិវាជ័យជំនះ៧មករា និងបានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកសំខាន់ៗរបស់កម្ពុជា ដើម្បីជំរុញឲ្យទំនាក់ទំនងរវាងសភានិងប្រទេសទាំងពីរ ឲ្យកាន់តែស៊ីជម្រៅ និងទូលំទូលាយបន្ថែមទៀត។ **ឯកឧត្តម** បានសម្តែងនូវអំណរសាទរដល់គណបក្សប្រជាជនកម្ពុជា ដែលទទួលបានការគាំទ្រពីប្រជាជនយ៉ាងច្រើនលើសលប់ នាពេលបោះឆ្នោតសាកល ឆ្នាំ២០១៨ កន្លងមកនេះ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តម** Muhammad Faruk Khan បានពិភាក្សាអំពីការជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យមួយចំនួន មានជាអាទិ៍ ពាណិជ្ជកម្ម វិនិយោគ កសិកម្ម ការងារ និងទេសចរជាដើម ដោយលើកទឹកចិត្តឲ្យក្រុមការងារស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ អនុវត្តឲ្យមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា (MOUs) មួយចំនួន ដែលបានចុះ

ហត្ថលេខារួចហើយ ក្នុងឱកាសដំណើរទស្សនកិច្ចរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅបង់ក្លាដែស ឆ្នាំ ២០១៤ និងដំណើរទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីបង់ក្លាដែស នៅកម្ពុជា ឆ្នាំ២០១៧។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តម** Muhammad Faruk Khan បានកត់សម្គាល់ដោយពេញចិត្តនូវការរីកចម្រើននៃទំនាក់ទំនងរវាងកម្ពុជា និងបង់ក្លាដែស តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចផ្លូវការរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ ហើយការដាក់ឈ្មោះផ្លូវមួយខ្សែនៅរាជធានីភ្នំពេញថា **«វិថី សេក មូជីប៊ូរ៉ាម៉ាន់»** តាមឈ្មោះបិតាជាតិបង់ក្លាដែស និងផ្លូវមួយខ្សែក្នុងរដ្ឋធានីដាក្កាថា **«វិថីព្រះនរោត្តម សីហនុ»** តាមព្រះនាមរបស់**ព្រះវររាជបិតាកម្ពុជា** នឹងជួយលើកកម្ពស់មិត្តភាពរវាងប្រទេសទាំងពីរថែមទៀត។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** សម្តែងក្តីសង្ឃឹមថា លោកជំទាវនាយករដ្ឋមន្ត្រីបង់ក្លាដែស នឹងអញ្ជើញចូលរួមក្នុងកិច្ចប្រជុំអាស៊ី-អឺរ៉ុបលើកទី១៣ (ASEM) នាចុងឆ្នាំនេះ នៅកម្ពុជា។

ឆ្លៀតឱកាសនោះ **ឯកឧត្តម ប្រធានគណៈប្រតិភូ** បានលើកឡើងអំពីបញ្ហាជនភៀសខ្លួនពីមីយ៉ាន់ម៉ា ដែលកំពុងជ្រកនៅក្នុងជំរុំក្នុងប្រទេសបង់ក្លាដែស និងបានស្នើឲ្យកម្ពុជាជួយជំរុញឲ្យមានដំណោះស្រាយសមស្រប ដើម្បីឲ្យពួកគេបានធ្វើមាតុភូមិនិវត្តន៍ក្នុងពេលឆាប់ៗ។

ជាការឆ្លើយតប **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍ថា កម្ពុជាបាន ហើយនឹងបន្តរួមចំណែកតាមរយៈយន្តការអាស៊ាន ដើម្បីជំរុញឲ្យជនភៀសខ្លួនពីមីយ៉ាន់ម៉ា បានធ្វើមាតុភូមិនិវត្តន៍ដោយឆាប់រហ័ស និងសុវត្ថិភាព។ កម្ពុជាសង្ឃឹមថា កិច្ចពិភាក្សារវាងបង់ក្លាដែស និងមីយ៉ាន់ម៉ា នឹងសម្រេចបានដំណោះស្រាយគ្រប់ជ្រុងជ្រោយមួយ ដើម្បីឲ្យជនភៀសខ្លួនដែលកំពុងជ្រកក្នុងជំរុំនៅបង់ក្លាដែសបានត្រឡប់ទៅរដ្ឋរ៉ាក់ខាញវិញ៕